# បច្ចេកទេសចិញ្ចឹមបង្កង
# ក្នុងស្រះ



មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប

បាទី ស្រុកពាមរក៏ ខេត្តព្រៃវែង

ឆ្នាំ ២០១១

# បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រះ

**រៀបរៀងដោយ៖**

**ជា ថារិទ្ធ** អនុប្រធានវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ

**សំ ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប

**ពិនិត្យ និងកែសម្រួលដោយ៖**

**សម នៅ** អគ្គនាយករង នៃរដ្ឋបាលជលផល

**មន្ត្រីបច្ចេកទេស** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម

រក្សាសិទ្ធិដោយ

**នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាសយដ្ឋានលេខ ១៨៦ មហាវិថីព្រះនរោត្តម ប្រអប់សំបុត្រ ៨៣៥

រាជធានីភ្នំពេញ

ទូរស័ព្ទ-ទូរសារ (៨៥៥) ២៣ ៩៩ ៣២ ២៤

# មាតិកាអត្ថបទ

**សេចក្ដីផ្ដើម**.......................................................................................-១-
**បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រះ**.........................................................-២-
**១. ការរៀបចំស្រះសម្រាប់ចិញ្ចឹម** ...................................................-៣-
១-១- ទីតាំងជីកស្រះ......................................................................-៣-
១-២- លក្ខណៈស្រះ........................................................................-៣-
១-៣- គុណភាពទឹក.........................................................................-៤-
១-៤- សម្ភារៈប្រើប្រាស់...................................................................-៥-
១-៥- ការរៀបចំស្រះ......................................................................-៥-
**២. ការជ្រើសរើសកូនបង្កងពូជ និងរបៀបលែង**...........................-៨-
២-១- ការជ្រើសរើសកូនបង្កងពូជ.......................................................-៨-
២-២- របៀបលែងកូនបង្កងដាក់ចិញ្ចឹម...............................................-៩-
**៣. ចំណី និងរបៀបផ្ដល់ចំណី**......................................................-១១-
៣-១- ចំណី .....................................................................................-១១-
៣-២- របៀបផ្ដល់ចំណី .....................................................................-១៣-
**៤. ការគ្រប់គ្រងគុណភាពទឹកស្រះ**...............................................-១៦-
ក-ការផ្លាស់ប្ដូរទឹក................................................................................- ១៦-
ខ-កត្តាសំខាន់ៗ នៃគុណភាពទឹក ...........................................................-១៧-
**៥. ការប្រមូលផលបង្កង**.............................................................-១៩-

## សេចក្ដីផ្ដើម

បង្កងស្ថិតក្នុងអំបូរ Palaemonidae ពូជ *Macrobrachium* និងស្ថិតក្នុងប្រភេទ *Macrobrachium rosenbergii*។ បង្កងរស់នៅ និងធំធាត់ក្នុងមជ្ឈដ្ឋានទឹកសាប ប៉ុន្តែបន្តពូជនៅតំបន់ទឹកភ្លាវ។ បង្កងមាននៅតាមបណ្ដាប្រទេសដែលមានអាកាសធាតុក្ដៅ ដូចជាប្រទេសវៀតណាម កម្ពុជា ថៃឡង់ដ៍ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ហ្វីលីពីន ឥណ្ឌា។ល។ នៅប្រទេសកម្ពុជា បង្កងសម្បូរនៅតាមដងទន្លេមេគង្គក្នុងខេត្តព្រៃវែង កណ្ដាល និងខេត្តតាកែវ។ បង្កងជាប្រភេទទំនិញមានតម្រូវការខ្ពស់នៅលើទីផ្សារគ្រប់ទីកន្លែង ដែលជាហេតុញ៉ាំងឱ្យ រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យកចិត្តទុកដាក់រៀបចំឯកសារ" **បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រែ** "នេះឡើង និងខិតខំជំរុញឱ្យកសិករ និងវារីវប្បករទូទៅបង្កើនការចិញ្ចឹមបង្កង ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ក្នុងគោលបំណងបង្កើនប្រាក់ចំណូលក្នុងគ្រួសារថែមទៀតផង។

**បច្ចេកទេសចិញ្ចឹមបង្កងក្នុងស្រះ**

ដើម្បីចិញ្ចឹមបង្កងដោយជោគជ័យ ចាំបាច់ត្រូវយកចិត្តទុកដាក់លើកត្តាសំខាន់ ៣ យ៉ាងគឺ: ការរៀបចំស្រះ ការគ្រប់គ្រងគុណភាពទឹក និងការផ្តល់ចំណី។

**រដូវកាលចិញ្ចឹម:** អាចចិញ្ចឹមបានពេញ ១ ឆ្នាំ អាស្រ័យដោយមានប្រភពទឹកគ្រប់គ្រាន់។

**វិធីសាស្ត្រចិញ្ចឹម:** ការចិញ្ចឹមបង្កងក្នុងស្រះមាន ៣ របៀបគឺការចិញ្ចឹមទ្រង់ទ្រាយតូច ឬ ជាលក្ខណៈគ្រួសារទ្រង់ទ្រាយមធ្យម និងទ្រង់ទ្រាយធំ ឬចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម។

**-ការចិញ្ចឹមទ្រង់ទ្រាយតូច ឬជាលក្ខណៈគ្រួសារ:** ជារបៀបចិញ្ចឹមដែលមិនចំណាយទុនច្រើនលើការទិញសម្ភារៈមកប្រើប្រាស់ ចំណី និងមិនទាមទារបច្ចេកទេសខ្ពស់។ ទិន្នផលអាចទទួលបានពី ២០០ ទៅ ៤០០ គីឡូក្រាម ក្នុង ១ ហិចតាក្នុង ១រដូវ រយៈពេលពី ៦ ទៅ ៨ ខែ។

**-ការចិញ្ចឹមទ្រង់ទ្រាយមធ្យម:** ស្រះត្រូវមានលក្ខណៈសមស្របតាមបច្ចេកទេស ទាមទារឱ្យមានបច្ចេកទេសក្នុងការចិញ្ចឹម និងចំណាយទុនច្រើន ដូចជាការទិញពូជ និងចំណី។ ទិន្នផលអាចទទួលបាន ពី ៦០០ ទៅ ១.៥០០គីឡូក្រាម ក្នុង ១ ហិចតា ក្នុង ១រដូវ រយៈពេលពី ៦ ទៅ ៨ ខែ។

**-ការចិញ្ចឹមទ្រង់ទ្រាយធំ ឬចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម:** ទាមទារត្រូវចំណាយទុនច្រើនលើការរៀបចំស្រះ ទិញកូនបង្កងពូជ ចំណី ទិញសម្ភារៈប្រើប្រាស់ដូចជាម៉ាស៊ីនបូមទឹក ម៉ាស៊ីនបង្កើនអុកស៊ីសែន ។ល។ និងទីតាំងស្រះចិញ្ចឹមត្រូវសមស្របតាមលក្ខណៈបច្ចេកទេស មានផ្ទៃដីធំទូលាយ និងអនុវត្តបច្ចេកទេសខ្ពស់។ ទិន្នផលអាចទទួលបានពី ២.០០០ ទៅ ៤.០០០ គីឡូក្រាម ក្នុង ១រដូវ រយៈពេលពី ៦ ទៅ ៨ ខែ។

## ១-ការរៀបចំស្រះសម្រាប់ចិញ្ចឹម

### ១-១- ទីតាំងជីកស្រះ

-ស្រះគួរជីកនៅតំបន់មានប្រភពទឹកពេញមួយឆ្នាំ ជាប្រភេទទឹកសាប ស្អាតល្អ គ្មានជាតិពុល តំបន់គ្មានប្រើថ្នាំកសិកម្ម និងគ្មានកាកសំណល់ពីរោងចក្រ និងអាចធ្វើការផ្លាស់ប្តូរទឹកបានដោយងាយស្រួល ដោយប្រើម៉ាស៊ីនបូម ឬអាចបញ្ចូលទឹកតាមរយៈរបបទឹកជោរនាច។ យើងអាចជ្រើសរើសទីតាំងចិញ្ចឹមនៅតំបន់ទឹកសាប ឬ តំបន់ទឹកភ្លាវ ដែលមានកំហាប់អំបិលមិនលើសពី ១០ ភាគពាន់ ។

-ទីតាំងជីកស្រះ ជាប្រភេទដីល្បាយដីឥដ្ឋ ឬ លាយខ្សាច់តិចតួច ដើម្បីអាចរក្សាទឹកបានយូរ និងគ្មានជាតិជូរ ។

-ទីតាំងស្រះ ត្រូវនៅក្បែរផ្លូវគមនាគមន៍ និងត្រូវមានអគ្គិសនីគ្រប់គ្រាន់ជាពិសេសសម្រាប់ការចិញ្ចឹមទ្រង់ទ្រាយមធ្យម និងទ្រង់ទ្រាយធំ។

### ១-២- លក្ខណៈស្រះ

-ស្រះត្រូវមានរាងចតុកោណកែង មានផ្ទៃក្រឡាចាប់ពី ១.០០០ ម៉ែត្រការេឡើងទៅ (ឬអាចមានទំហំតូចជាងនេះក៏បានដែរ សម្រាប់ការចិញ្ចឹមទ្រង់ទ្រាយតូច) និងមានជម្រៅទឹកពី ១.២ ទៅ ១.៥ ម៉ែត្រ។ បាតស្រះត្រូវមានកម្រិតជម្រាលទៅជ្រុងម្ខាង ដើម្បីងាយស្រួលបញ្ចេញទឹកចោល។ នៅបាតស្រះត្រូវមានជីកប្រឡាយសម្រាប់នាំទឹកពីកន្លែងបញ្ចូលទឹករហូតដល់កន្លែងបញ្ចេញទឹកចោល។ ប្រឡាយគួរមានទទឹងពី ២ ទៅ ៣ ម៉ែត្រ និងត្រូវមានជម្រៅជ្រៅជាងបាតស្រះពី ១០ ទៅ ១៥ សង់ទីម៉ែត្រ។ បាតស្រះ ត្រូវមានភក់ ឬ មមោកតិច។

ខ្នងភ្លឺស្រះត្រូវមានទំហំយ៉ាងតិច ២ ម៉ែត្រ មានលក្ខណៈរឹងមាំល្អ គ្មានរន្ធសត្វផ្សេងៗ និងមិនជ្រាបទឹក។

-ស្រះចិញ្ចឹមនីមួយៗ ត្រូវមានប្រព័ន្ធបញ្ចេញបញ្ចូលទឹក។ បំពង់បញ្ចេញទឹកចោលត្រូវនៅផ្នែកទាបបំផុត ហើយបំពង់បញ្ចូលទឹកត្រូវនៅផ្នែកខាងទីខ្ពស់។

## ១-៣- គុណភាពទឹក

បង្កងជាប្រភេទវារីសត្វរស់ក្នុងមជ្ឈដ្ឋានទឹកសាប ប៉ុន្តែវាក៏អាចរស់នៅ និងធំធាត់បានក្នុងតំបន់ទឹកភ្លាវ ដែលមានកំហាប់អំបិលរហូតដល់ ១0 ភាគពាន់។ បង្កងមានចរិតរស់នៅស្រទាប់បាត ក្នុងមជ្ឈដ្ឋានទឹកស្អាត និងត្រូវមានកត្តាគុណភាពទឹកសំខាន់ៗផ្សេងទៀតដូចខាងក្រោម :

**-សីតុណ្ហភាព:** សមស្របពី ២២ ទៅ ៣២ អង្សាសេ និងល្អបំផុតពី ២៦-៣0 អង្សាសេ។ បើសិនជាសីតុណ្ហភាពទឹកក្រោម ១៦ អង្សាសេ ឬ លើសពី ៤0 អង្សាសេ ហើយកម្រិតសីតុណ្ហភាពទឹកនេះអូសបន្លាយយូរថ្ងៃអាចធ្វើឱ្យបង្កងងាប់បាន។

**- កម្រិត pH ឬ កម្រិតជាតិជូរ:** សមស្របមានពី ៧ ទៅ ៨ ។ បង្កងមិនអាចរស់នៅក្នុងមជ្ឈដ្ឋានទឹកដែលមានកម្រិត pH ឬកម្រិតជាតិជូរក្រោម ៥ បានឡើយ។

**- កំហាប់អំបិល:** កំហាប់អំបិលសមស្របសម្រាប់ការលូតលាស់របស់បង្កងមិនលើសពី ៥ ភាគពាន់។ ជាធម្មតាបង្កងក៏អាចធន់ និងរស់នៅបានក្នុងទឹកដែលមានកំហាប់អំបិលរហូតដល់ ២0 ភាគពាន់ ប៉ុន្តែត្រូវបង្កើនកម្រិតកំហាប់អំបិលនេះឡើងសន្សឹមៗ បើមិនដូច្នោះទេអាចធ្វើឱ្យបង្កងងាប់បាន។

**-បរិមាណអុកស៊ីសែនក្នុងទឹក:** បង្កងចូលចិត្តរស់នៅក្នុងមជ្ឈដ្ឋានផ្ទៃទឹកធំទូលាយ ដែលមានកម្រិតអុកស៊ីសែនលើសពី ៥ មិល្លីក្រាមក្នុង ១លីត្រ និងកម្រិតអុកស៊ីសែនតិចបំផុតរបស់បង្កងគឺ ៣ មិល្លីក្រាមក្នុង ១ លីត្រ។ កម្រិតអុកស៊ីសែននេះ គឺខ្ពស់ជាងកម្រិតអុកស៊ីសែននៃប្រភេទត្រីទឹកសាបស្ទើរតែទាំងអស់ដែលមានតែ ២ មិល្លីក្រាមក្នុង ១ លីត្រប៉ុណ្ណោះ។ បើបរិមាណអុកស៊ីសែនក្នុងទឹកទាបជាង ១.៥ មិល្លីក្រាមក្នុង ១ លីត្រ ធ្វើឱ្យបង្កងងើបក្បាលលើផ្ទៃទឹក និងក្រោម ១.២ មិល្លីក្រាមក្នុង ១ លីត្រ ធ្វើឱ្យបង្កងងាប់ ។

**-កម្រិតរឹងនៃទឹក** ($CaCO_3$)**:** ទឹកមានកម្រិតរឹងពី ៥0-១00 មិល្លីក្រាម ក្នុង ១ លីត្រ គឺសមស្របសម្រាប់បង្កង។

**-សារធាតុរ៉ែ (លោហៈធាតុ):** បង្កងមិនអាចបន្សាំនឹងសារធាតុរ៉ែ (លោហៈធាតុ) ទេជាពិសេសគឺជាតិដែក។ បរិមាណសារធាតុដែកមាន 0.១ ទៅ 0.២ មិល្លីក្រាមក្នុង ១ លីត្រទឹក គឺសមស្របសម្រាប់បង្កង បើលើសពី ៤ មិល្លីក្រាម ក្នុង ១ លីត្រ នឹងបង្កគ្រោះថ្នាក់ដល់បង្កង។

## ១-៤- សម្ភារៈប្រើប្រាស់

អ្នកចិញ្ចឹមបង្កងត្រូវមានម៉ាស៊ីនបូមទឹកសម្រាប់ផ្លាស់ប្តូរទឹកតាមពេលវេលាកំណត់ ឬ សម្រាប់ប្តូរទឹក នៅពេលទឹកស្រះអន់គុណភាព។ ម៉ាស៊ីនបូមទឹកគួរមានទំហំល្មម ដើម្បីងាយស្រួលចល័ត និងដឹកជញ្ជូន។

## ១-៥- ការរៀបចំស្រះ

ការរៀបចំស្រះ ជាកត្តាសំខាន់ដែលត្រូវយកចិត្តទុកដាក់ ដើម្បីបង្កើតមជ្ឈដ្ឋានសមស្របសម្រាប់ការលូតលាស់របស់បង្កង។ ការរៀបចំស្រះមានរបៀប

ដូចខាងក្រោម :

-សំអាតស្មៅ កំទេចកំទីក្នុងស្រះ និងសំអាតរុក្ខជាតិដែលមាននៅជុំវិញភ្លឺស្រះ។ បូមពង្រីងស្រះចាប់ត្រីល្អិត ត្រីកាច (ដូចជា ត្រីរ៉ស់ ផ្ទក់ អណ្តែងក្រាញ់។ល។) និងអន្ទង់ ពស់ កង្កែបចេញ។

-ចំពោះស្រះចាស់ត្រូវស្តារល្បាប់ភក់បាតស្រះចេញ ដើម្បីបំបាត់មេរោគឧស្ម័នពុល ដោយរក្សាទុកកម្រាស់ល្បាប់ភក់ពី ១0 ទៅ ១៥ សង់ទីម៉ែត្រ។

-ត្រូវជួសជុលភ្លឺស្រះឱ្យបានមាំល្អ លប់រន្ធ ឬប្រហោងផ្សេងៗនៅតាមភ្លឺស្រះ។ ភ្លឺស្រះត្រូវមានកម្ពស់ខ្ពស់ជាងទឹកស្រះយ៉ាងតិច 0.៥ ម៉ែត្រ ។

-ក្រោយពីស្តារល្បាប់ភក់រួច ត្រូវហាលស្រះពី ២ ទៅ ៧ ថ្ងៃ ដើម្បីបំភាយឧស្ម័នពុលផ្សេងៗ ដូចជាអ៊ីដ្រូសែនស៊ុលផួ ($H_2S$) អាម៉ូញ៉ាក់ ($NH_3$) មេតាន ($CH_4$)...ចេញពីស្រះ។ បើស្រះមានជាតិជូរមិនគួរហាលថ្ងៃយូរពេកទេ ។



*ការបូមទឹកពង្រីង-ចាប់ត្រីកាច-ស្តារភក់*



*ការសំអាតស្មៅ-រុក្ខជាតិជុំវិញស្រះ*

**-ការបាចកំបោរបាតស្រះ:** ប្រើកំបោរសបាចឱ្យសព្វបាតស្រះ ដើម្បីសម្លាប់មេរោគ និងកែលំអកម្រិត pH ឬ កម្រិតជាតិជូរនៃទឹក។ ចំពោះស្រះថ្មី

ត្រូវបាចកំបោរក្នុងបរិមាណពី ៣ ទៅ ៥ គីឡូក្រាម ក្នុង ១០០ ម៉ែត្រការេ និង ចំពោះស្រះចាស់គួរប្រើកំបោរក្នុងបរិមាណពី ៧ ទៅ ១០ គីឡូក្រាម ក្នុង ១០០ ម៉ែត្រការេ ។





*បញ្ចូលទឹកដោយច្រោះនឹងស្បៃ* *គុណភាពទឹកស្រះក្រោយពេលរៀបចំ*

-**ការដាក់ជីះ** ក្រោយពេលរៀបចំស្រះរួច ត្រូវដាក់ជីដើម្បីបង្កើតចំណីធម្មជាតិ។ ប្រភេទជីដែលល្អ គឺជីលាមកសត្វ មាន់ ទា និងជ្រូក។ល។ ក្នុងបរិមាណពី ២៥ ទៅ ៣០ គីឡូក្រាម ក្នុង ១០០ ម៉ែត្រការេ។ បើសិនជាគ្មានជីលាមកសត្វ យើងក៏អាចប្រើជីគីមី NPK ក្នុងបរិមាណពី ២ ទៅ ៤ ក្រាម ក្នុង ១ម៉ែត្រគូប ដោយត្រូវត្រាំជីក្នុងទឹកឱ្យរលាយគ្រាប់អស់សិន រួចបាចឱ្យសព្វពេញផ្ទៃស្រះ។

-**ការបញ្ចូលទឹកក្នុងស្រះ** ក្រោយពេលដាក់ជីរួចបាន ១ ថ្ងៃ យើងត្រូវបញ្ចូលទឹកក្នុងស្រះឱ្យបានពី ៣០ ទៅ ៤០ សង់ទីម៉ែត្រ។ ក្រោយពីបាចជីរួច រយៈពេលពី ២ ទៅ ៣ថ្ងៃ រុក្ខជាតិប្លង់តុងបានកើតមានដែលធ្វើឱ្យទឹកស្រះមានពណ៌បៃតងខ្ចី រួចយើងត្រូវបញ្ចូលទឹកបំពេញស្រះ។



*ការបាចកំបោរបាតស្រះថ្មី*



*ការបាចកំបោរបាតស្រះចាស់*

***ចំណាំ:*** *ពេលបញ្ចូលទឹកក្នុងស្រះ ត្រូវច្រោះនឹងស្បៃក្រឡាល្អិតទំហំ 0.៥ មិល្លីម៉ែត្រ ដើម្បីការពារត្រីល្អិត កំពឹស និងសត្វចង្រៃផ្សេងៗចូលក្នុងស្រះ ដែលបានរៀបចំហើយ ។*

-ត្រូវរៀបចំមែកឈើ ឬឬស្សីដោយចងជាបាច់ដាក់នៅបាតស្រះសម្រាប់ជាជម្រកនៅពេលបង្កងសក។ ម៉្យាងទៀត យើងអាចដាក់បន្ថែមរុក្ខជាតិទឹក ដូចជា ចក ត្រកួន ដើម្បីជាចំណីបន្ថែម និងជាជម្រកសម្រាប់បង្កង។បន្ទាប់មកត្រូវត្រៀមលក្ខណៈលែងកូនបង្កងពូជក្នុងស្រះ ដែលបានរៀបចំហើយនោះ ។

## ២_ការជ្រើសរើសកូនបង្កងពូជ និងរបៀបលែង

### ២- ១-ការជ្រើសរើសកូនបង្កងពូជ

ដើម្បីចិញ្ចឹមបង្កងឱ្យទទួលបានគុណភាពល្អ យើងត្រូវយកចិត្តទុកដាក់ចំណុចសំខាន់ៗដូចខាងក្រោម :

-គួរទិញកូនបង្កងពូជពីកសិដ្ឋានផលិតពូជដែលមានទំនុកចិត្ត និងមានលិខិត

បញ្ជាក់អំពីគុណភាព។ បើសិនមានលទ្ធភាពយើងគួរជ្រើសរើសយក តែកូនបង្កងពូជឈ្មោលសុទ្ធសម្រាប់ដាក់ចិញ្ចឹម ពីព្រោះវាលូតលាស់លឿន។

- ម៉្យាងទៀតត្រូវជ្រើសរើសកូនបង្កងពូជដាក់ចិញ្ចឹមឱ្យមានប្រវែងចាប់ពី ៣ សង់ទីម៉ែត្រឡើងទៅ ដែលមានទំហំប៉ុនគ្នា មានសុខភាពល្អ គ្មានរបួសស្នាម និងមានពុកមាត់ ជើង និងដង្កៀបគ្រប់គ្រាន់ ។



*កូនបង្កងពូជសម្រាប់ដាក់ចិញ្ចឹម*

**លក្ខណៈសំគាល់កូនបង្កងមានសុខភាពល្អ**

-ជាទូទៅ គឺពុកមាត់របស់វាជានិច្ចកាលមានលក្ខណៈស្របគ្នា។ បើសិនជាពុកមាត់របស់វាមានរាងជាអក្សរវ៉េ (V) បញ្ជាក់ថាកូនបង្កងមានសុខភាពខ្សោយ។

-មានសកម្មភាពហែលរហ័សរហួន។ នៅពេលផ្តាច់ចរន្តខ្យល់អុកស៊ីសែនកូនបង្កងមានសុខភាពល្អ តែងតែឡើងមកផ្នែកខាងលើនៃផ្ទៃទឹក ។

-ម៉្យាងទៀត កូនបង្កងមានសុខភាពល្អ គឺគេសំគាល់នៅលើដងខ្លួនរបស់វាមានពណ៌ខៀវថ្លា។ ចំពោះកូនបង្កងមានជំងឺ គឺដងខ្លួនរបស់វាមានពណ៌សស្រអាប់ ហើយគំរបកំភ្លៀងរបស់វាមានពណ៌ខ្មៅ។

## ២-២- របៀបលែងកូនបង្កងដាក់ចិញ្ចឹម

-មុនពេលលែងកូនបង្កង ត្រូវធ្វើការត្រួតពិនិត្យគុណភាពទឹកស្រះជាមុនសិន។ បើសិនជាទឹកស្រះមានលក្ខណៈល្អ ក្រោយពេលស្រះបានរៀបចំហើយ គឺយើងអាចលែងកូនបង្កងចូលស្រះបាន។

-ក្នុងករណីដែលកូនបង្កងពូជដឹកជញ្ជូនដោយដាក់ក្នុងថង់ប្លាស្ទិច និងមានបញ្ចូលខ្យល់អុកស៊ីសែន មុននឹងលែងកូនបង្កងចូលក្នុងស្រះ យើងត្រូវត្រាំថង់កូនបង្កងក្នុងទឹកស្រះរយៈពេលពី ១០ ទៅ ១៥ នាទីជាមុនសិន ដើម្បីឱ្យសីតុណ្ហភាពទឹកក្នុងថង់បន្សាំនឹងសីតុណ្ហភាពទឹកក្នុងស្រះ។ បន្ទាប់មកទើបយើងចាប់ផ្តើមបើកមាត់ថង់ឱ្យកូនបង្កងហែលចេញតាមសម្រួល។ គេត្រូវលែងកូនបង្កងចម្ងាយប្រហែល ២ ម៉ែត្រ ពីមាត់ស្រះ ដើម្បីចៀសវាងកុំឱ្យវាលោតឡើងលើមាត់ស្រះ។ ត្រូវលែងកូនបង្កងនៅពេលអាកាសធាតុត្រជាក់ ជាពិសេសគឺនៅពេលព្រឹក ។

**-ដង់ស៊ីតេដាក់ចិញ្ចឹម៖** សម្រាប់ការចិញ្ចឹមជាលក្ខណៈគ្រួសារដង់ស៊ីតេកូនបង្កងដាក់ចិញ្ចឹមមានពី ៣ ទៅ ៥ក្បាលក្នុង ១ ម៉ែត្រការេ ។ សម្រាប់ការចិញ្ចឹមទ្រង់ទ្រាយមធ្យម បរិមាណកូនបង្កងដាក់ចិញ្ចឹមមានពី ៥ ទៅ ៧ ក្បាលក្នុង ១ ម៉ែត្រការេ និងសម្រាប់ការចិញ្ចឹមទ្រង់ទ្រាយធំ ឬចិញ្ចឹមជាលក្ខណៈឧស្សាហកម្មបរិមាណកូនបង្កងដាក់ចិញ្ចឹមគឺពី ១២ ទៅ ១៥ ក្បាល ក្នុង ១ ម៉ែត្រការេទឹកស្រះ។

**ការចិញ្ចឹមចម្រុះជាមួយត្រី៖**

- យើងអាចចិញ្ចឹមបង្កងជាមួយប្រភេទត្រីផ្សេងៗបាន ដើម្បីប្រើប្រាស់ឱ្យអស់នូវចំណីដែលមានក្នុងស្រះ និងដើម្បីជួយកែលំអគុណភាពទឹកស្រះ។ ការ

ចិញ្ចឹមចម្រុះនេះ យើងអាចដាក់ត្រីចិញ្ចឹមបានតែក្នុងស្រះចិញ្ចឹមបង្កង ដែលចិញ្ចឹមជាទ្រង់ទ្រាយតូច និងមធ្យមប៉ុណ្ណោះ។

-សម្រាប់ប្រភេទត្រីដាក់ចិញ្ចឹមចម្រុះជាមួយបង្កង គឺជាប្រភេទត្រីដែលរស់នៅស្រទាប់លើ និងស្រទាប់កណ្តាល និងជាប្រភេទត្រីដែលមិនប្រជែងចំណីជាមួយបង្កង ដូចជា ប្រភេទត្រីកាបស កាបក្បាលធំ កាបស៊ីស្មៅ និងត្រីឆ្ពិនជាដើម ។

-ដង់ស៊ីតេត្រីដាក់ចិញ្ចឹម គឺ ១ក្បាលក្នុង ៥ ទៅ ១០ ម៉ែត្រការេនៃផ្ទៃទឹកស្រះ។

## ៣-ចំណី និងរបៀបផ្តល់ចំណី

ត្រូវផ្តល់ចំណីគ្រប់ល្មម ចៀសវាងផ្តល់ចំណីលើស ពីព្រោះចំណីដែលនៅសល់ច្រើនក្នុងស្រះ អាចបំលែងជាធាតុពុលបង្កឱ្យកើតមានរុក្ខជាតិប្លង់តុងច្រើន ធ្វើឱ្យបង្កងពិបាកសក និងលូតលាស់មិនល្អ។ ដូចនេះ ការផ្តល់ចំណីខ្វះបន្តិចប្រសើរជាងការផ្តល់ចំណីលើស ។

### ៣-១- ចំណី

ដើម្បីឱ្យបង្កងសក និងមានការលូតលាស់ល្អ ចំណីត្រូវមានសារធាតុបំប៉នសំខាន់ៗដូចជា: **ប្រូតេអ៊ីន** ពី ៣០ ទៅ ៣៥ ភាគរយ **លីពីត** ៣ ទៅ ៥ ភាគរយ **កាល់ស្យូម** ២ ទៅ ៣ ភាគរយ **ផូស្វរ** ១ ទៅ ១.៥ ភាគរយ និង **សែលុយឡូស** ពី ៣ ទៅ ៥ ភាគរយ។ យើងអាចប្រើចំណីគ្រាប់ ចំណីកែច្នៃ និងចំណីស្រស់ដែលមានសារធាតុដូចខាងលើ។ ចំពោះចំណីគ្រាប់មានបរិមាណសារធាតុបំប៉នមិនប្រែប្រួល និងងាយស្រួលប្រើប្រាស់ ប៉ុន្តែមានតម្លៃខ្ពស់។ រីឯចំណីកែច្នៃ និង

ចំណីស្រស់មានតម្លៃថោកជាងចំណីគ្រាប់ ព្រោះយើងអាចរកបាននៅតាមមូលដ្ឋាន តែប្រភេទចំណីនេះមានបរិមាណសារធាតុបំប៉នប្រែប្រួល ដែលធ្វើឱ្យយើងចំណាយពេលវេលាច្រើនក្នុងការផ្តល់ចំណី។ ការផ្សំចំណីអាស្រ័យលើវត្ថុធាតុដើមដែលមាននៅតាមមូលដ្ឋាន និងមានរូបមន្តផ្សំចំណីផ្សេងៗគ្នា ប៉ុន្តែចាំបាច់ត្រូវធានាឱ្យមាននូវបរិមាណសារធាតុបំប៉នសំខាន់ៗ ដូចជាៈ ម្សៅគ្រាប់ធញ្ញជាតិ ៦៥ ភាគរយ ម្សៅត្រី ២៥ ភាគរយ និងប្រភេទសារធាតុផ្សេងៗទៀតចំនួន ១០ ភាគរយ។ បន្ទាប់មក យើងអាចកែច្នៃតាមរូបមន្តដូចខាងក្រោមៈ

- ម្សៅសណ្តែកសៀង : ២០ %
- កន្ទក់ : ៣៥ %
- ម្សៅមី : ១០ %
- ម្សៅត្រី : ២៥ %
- ម្សៅឆ្អឹង : ២ %
- ម្សៅគ : ៥ %
- ព្រីមិុច (Premix) : ២ %
- និងសារធាតុខ្លាញ់ ( ខ្លាញ់ត្រី មឹក ប្រេងដូង ) : ១ %



*ឧបករណ៍ផលិតចំណីគ្រាប់*



*ការសម្ងួតចំណីគ្រាប់*

## ៣-២- របៀបផ្តល់ចំណី

ចំណីគ្រាប់ ឬ ចំណីកែច្នៃត្រូវផ្តល់ឱ្យបង្កងនៅខែដំបូង និងខែបន្ទាប់។ ចំណែកប្រភេទចំណីស្រស់មានដូចជា ត្រីល្អិត កំពឹស ក្តាម ខ្យង។ល។ដែលមានតម្លៃថោកនៅរដូវវស្សាក៏អាចផ្តល់ជាចំណីបង្កងបានដែរ។ ចំណីស្រស់មានគុណភាពធ្វើឱ្យបង្កងមានការលូតលាស់លឿន និងបានកាត់បន្ថយការចំណាយលើការទិញចំណីគ្រាប់ ប៉ុន្តែចំណីស្រស់ងាយធ្វើឱ្យខូចគុណភាពទឹកស្រះផងដែរ ។

- **កន្ត្រងចំណី:** ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងបរិមាណចំណីដែលត្រូវផ្តល់ឱ្យបង្កងស៊ី យើងត្រូវដាក់កន្ត្រងចំណីចំនួន ៤ នៅតាមជ្រុងស្រះ ហើយកន្ត្រងនីមួយៗត្រូវដាក់ឱ្យផុតពីបាតស្រះកម្ពស់ ១០ សង់ទីម៉ែត្រ។ កន្ត្រងនីមួយៗគួរមានទំហំ ១ ម៉ែត្រការេ។ រាល់ពេលផ្តល់ចំណីត្រូវបាចចំណីឱ្យសព្វពេញផ្ទៃស្រះ និងត្រូវដាក់ចំណីបន្ថែមនៅក្នុងកន្ត្រងចំណីប្រហែល ១ ភាគរយនៃបរិមាណចំណីសរុប។ ក្រោយពីផ្តល់ចំណីបានរយះពេល ១ ម៉ោង ត្រូវត្រួតពិនិត្យមើលកន្ត្រងចំណី បើសិនជាបង្កងទើបតែស៊ីចំណីអស់បញ្ជាក់ថា ចំណីគ្រប់ល្មមសម្រាប់បង្កង។ បើសិនជាចំណីនៅសល់ច្រើន គឺត្រូវបន្ថយចំណីនៅពេលដាក់ចំណីលើកក្រោយ។ ប៉ុន្តែបើបង្កងស៊ីចំណីអស់លឿន យើងត្រូវបង្កើនបរិមាណចំណីនៅពេលដាក់ចំណីលើកក្រោយ។
- **អត្រាផ្តល់ចំណី:** ត្រូវផ្តល់ចំណីឱ្យបង្កងស៊ីចំនួន ២ ដង ក្នុង១ថ្ងៃ គឺនៅម៉ោង ៥ ព្រឹក និងម៉ោង ៥ ល្ងាច ។ ពេលព្រឹកត្រូវផ្តល់ចំណី ៣០ ភាគរយ នៃបរិមាណចំណីទាំងអស់ និងនៅពេលល្ងាចផ្តល់ ៧០ ភាគរយ នៃបរិមាណចំណីដែលនៅសល់។ បរិមាណចំណីត្រូវផ្តល់ឱ្យបង្កងរាល់ថ្ងៃ ទៅតាម

ដំណាក់កាលលូតលាស់របស់វា និងគិតតាមទំងន់បង្កងសរុបដែលមាននៅក្នុងស្រះ (មើលតារាងទី ១ ខាងក្រោម)។

-មុនពេលដាក់ចំណីក្នុងកន្ទ្រង ត្រូវសំអាតកន្ទ្រងឱ្យបានស្អាតជាមុនសិន រួចទើបដាក់ចំណីថ្មីចូល។

**តារាងទី ១៖ បរិមាណចំណី និងអត្រារស់របស់បង្កង**

| **រយៈពេលចិញ្ចឹម** (ថ្ងៃ) | **ទម្ងន់មធ្យម** (ក្រាម) | **អត្រារស់** (%) | **បរិមាណចំណី** (%) |
|---|---|---|---|
| ១ ដល់ ២០ | ៤ | ១០០ | ២០ |
| ២១ ដល់ ៤០ | ៧ | ៩៥ | ១៥ |
| ៤១ ដល់ ៦០ | ១៣ | ៩០ | ១០ |
| ៦១ ដល់ ៨០ | ២២ | ៨៥ | ៨ |
| ៨១ ដល់ ១០០ | ៣១ | ៨០ | ៥ |
| ១០១ ដល់ ១២០ | ៤០ | ៧៥ | ៤ |
| ១២១ ឡើង | លើ ៥០ | ៧០ | ៣ |



*ការផ្តល់ចំណីដោយប្រើកន្ត្រង*



*ប្រភេទចំណីស្រស់*

## ប្រការដែលត្រូវចងចាំនៅពេលដាក់ចំណី

- **ចំណីកែច្នៃ:** ត្រូវលាយច្របល់ចំណីបញ្ចូលគ្នាឱ្យសព្វ និងត្រូវមានដាក់ម្សៅស្អិត (ម្សៅគ) រួចកិនចេញជាគ្រាប់សម្រាប់ផ្តល់ឱ្យបង្កងស៊ី។ ប្រភេទចំណីដែលកែច្នៃរួចនេះ គឺសម្រាប់ប្រើតែ ១ ថ្ងៃប៉ុណ្ណោះ ។
- **ចំណីស្រស់:** ត្រូវលាងចំណីស្រស់ឱ្យស្អាត និងកាត់ជាដុំល្អិត១ ទើបដាក់ឱ្យបង្កងស៊ី។ មិនត្រូវយកចំណីដែលងាប់ ឬ ខូចគុណភាពមកធ្វើជាចំណីបង្កងឡើយ ។
- **ចំណីគ្រាប់:** ចំពោះចំណីគ្រាប់មិនត្រូវប្រើចំណីណាដែលហួសពេលកំណត់ប្រើប្រាស់ ឬដុះផ្សិតឡើយ។
- **ការចាប់ចំណី:** បង្កងចាប់យកចំណីដោយស្រង់ក្លិន ដូចនេះចំពោះចំណីកែច្នៃយើងអាចលាយវាជាមួយចំណីស្រស់ ដើម្បីឱ្យចំណីកែច្នៃមានក្លិនដែលងាយទាក់ទាញឱ្យបង្កងស៊ី។
- **ការប្រើប្រាស់វីតាមីន:** ដើម្បីបង្កើនសុខភាពរបស់បង្កង និងចៀសផុតពីជំងឺផ្សេង១ យើងអាចប្រើវីតាមីនសេ C លាយជាមួយចំណីបាន។

**-ការត្រួតពិនិត្យការលូតលាស់របស់បង្កងៈ** យើងអាចកំណត់រយៈពេល ២០ ថ្ងៃម្តង ដើម្បីចាប់បង្កងមួយចំនួនពីកន្ទ្រងចំណីទាំង ៤ យកមកថ្លឹង និងគិតរកទម្ងន់មធ្យម ។ បន្ទាប់មក ផ្អែកលើអត្រារស់របស់បង្កង ដែលមានបញ្ជាក់នៅក្នុងតារាងទី១ យើងអាចគណនាទម្ងន់បង្កងសរុបដែលមានក្នុងស្រះ ហើយបន្ទាប់មក យើងអាចគណនាបរិមាណចំណីដែលត្រូវផ្តល់ឱ្យបង្កងស៊ីនៅដំណាក់កាលបន្ទាប់ ។

## ៤-ការគ្រប់គ្រងគុណភាពទឹកស្រះ

បង្កងលូតលាស់ និងធំធាត់អាស្រ័យទៅលើការ**សក**របស់វា ។ ដើម្បីធ្វើឱ្យបង្កង**សក**បានដោយងាយ ចាំបាច់ត្រូវគ្រប់គ្រងគុណភាពទឹកស្រះឱ្យបានល្អ ដែលជាកត្តាសំខាន់ចាំបាច់បំផុត ។ ខាងក្រោមនេះ គឺជាវិធីសាស្ត្រមួយចំនួនក្នុងការគ្រប់គ្រងគុណភាពទឹកស្រះឱ្យបានល្អៈ

### ក-ការផ្លាស់ប្តូរទឹក

-ការផ្លាស់ប្តូរទឹក គឺមានគោលបំណងដើម្បីកាត់បន្ថយភាពក្រខ្វក់នៃទឹកស្រះ ធ្វើឱ្យទឹកស្រះថ្លាល្អ បង្កើនបរិមាណខ្យល់អុកស៊ីសែនក្នុងស្រះ និងបានបញ្ចេញចោលឧស្ម័នពុលផ្សេងៗដូចជា អ៊ីដ្រូសែនស៊ុលផួ ($H_2S$) អាម៉ូញ៉ាក់ ($NH_3$) ឧស្ម័នកាបូនិច ($CO_2$) ជាដើម ។ល ។ ជាធម្មតា នៅខែដំបូង យើងមិនចាំបាច់ផ្លាស់ប្តូរទឹកទេ ព្រោះលាមករបស់បង្កងនៅបាតស្រះមានបរិមាណតិចតួចនៅឡើយ ។ នៅខែទី ២ ត្រូវប្តូរទឹកឱ្យបានញឹកញាប់ ឬ រៀងរាល់ថ្ងៃ ។ បរិមាណទឹកត្រូវប្តូរអាស្រ័យលើគុណភាពទឹកស្រះ និងទំហំនៃការចិញ្ចឹម ។ ជាទូទៅ យើងអាចប្តូរទឹកពី ១០ ទៅ ២០ ភាគរយ នៃផ្ទៃ

ទឹកស្រះ។ ការប្តូរទឹកនេះ គឺត្រូវបូមយកលាមកបង្កង និងកាកសំណល់ផ្សេងៗទៀតចេញពីផ្នែកបាតស្រះ និងបញ្ចូលទឹកថ្មីមកវិញនៅផ្នែកខាងលើនៃផ្ទៃស្រះ ដោយមានប្រើស្បៃច្រោះទឹកដែលបង្ហូរចូល។

-ការដាក់ចិញ្ចឹមបង្កងក្នុងកម្រិតដង់ស៊ីតេខ្ពស់ ត្រូវធ្វើការផ្លាស់ប្តូរបរិមាណទឹកច្រើនជាងការចិញ្ចឹមបង្កងក្នុងកម្រិតដង់ស៊ីតេទាប។ ចំពោះការចិញ្ចឹមដោយប្រើចំណីស្រស់ងាយធ្វើឱ្យខូចគុណភាពទឹកណាស់ ដូចនេះចាំបាច់ត្រូវផ្លាស់ប្តូរទឹកឱ្យបានច្រើនដែរ ។

## ខ-កត្តាសំខាន់ៗ នៃគុណភាពទឹក

ជានិច្ចកាល យើងត្រូវត្រួតពិនិត្យកត្តាសំខាន់ៗនៃគុណភាពទឹក ដូចជាសីតុណ្ហភាព pH (កម្រិតជាតិជូរនៃទឹក) កម្រិតរលាយខ្យល់អុកស៊ីសែនក្នុងទឹក កម្រិតរឹងនៃទឹក។ល។ ដើម្បីកែលំអទាន់ពេលវេលានៅពេលគុណភាពទឹកមានការប្រែប្រួល ។

**-កម្រិត pH (កម្រិតជាតិជូរនៃទឹក):** ជានិច្ចកាលមានការប្រែប្រួលដោយសារការកើនឡើងនៃរុក្ខជាតិបួង់តុងដែលធ្វើឱ្យ pH ខ្ពស់ និង pH ចុះទាប ដោយមានការបំភាយនៃសមាសធាតុសរីរាង្គនៅបាតស្រះ។ ម៉្យាងទៀតទឹកស្រះមានជាតិអាស៊ីត ឬជាតិជូរ ឬ pH ចុះទាប ដោយសារទឹកភ្លៀង ឬ ប្រភពទឹកផ្សេងៗ។ ដូចនេះ ត្រូវរក្សាកម្រិត pH ទឹកស្រះឱ្យបានល្អឱ្យនៅចន្លោះពី ៧ ទៅ ៨ ។ បើសិន pH ក្រោម ៧ ឬ លើពី ៩ នឹងជះឥទ្ធិពលអាក្រក់ដល់បង្កង។ ដើម្បីកែលំអ pH ត្រូវផ្លាស់ប្តូរទឹក ឬ ប្រើប្រាស់កំបោរ។ បើសិនជារុក្ខជាតិបួង់តុងកើតមានច្រើនធ្វើឱ្យ pH ឡើងខ្ពស់ត្រូវប្តូរទឹកជាថ្មី។ មុនពេលភ្លៀង ត្រូវបាចកំបោរសនៅជុំវិញស្រះ ដើម្បីការពារ

ជាតិជូរហួរពីមាត់ស្រះ។ ក្រោយពេលភ្លៀង ត្រូវវាស់កម្រិត pH បើសិន pH ក្រោម ៧ គឺត្រូវប្រើកំបោរសពី១ ទៅ ១.៥ គីឡូក្រាម ក្នុង១០០ ម៉ែត្រការេ ដោយត្រូវលាយជាមួយទឹកឱ្យរលាយអស់ រួចបាចឱ្យសព្វពេញផ្ទៃស្រះដើម្បីបង្កើនកម្រិត pH ។

**-កម្រិតខ្យល់អុកស៊ីសែនក្នុងទឹកៈ** កង្វះខ្យល់អុកស៊ីសែនក្នុងទឹកស្រះ ធ្វើឱ្យបង្កងងើបនៅលើផ្ទៃទឹក និងអាចបណ្ដាលឱ្យបង្កងងាប់។ បញ្ហានេះងាយកើតមានណាស់នៅតាមស្រះចិញ្ចឹមបង្កង។ មូលហេតុដែលកង្វះខ្យល់អុកស៊ីសែន ក្នុងស្រះបណ្ដាលមកពី ស្រះសម្បូរដោយសារធាតុសរីរាង្គមានចំណីសល់ច្រើនក្នុងស្រះ និងមានរុក្ខជាតិប្លង់តុងកើតមានច្រើន។ល។ កម្រិតរលាយខ្យល់អុកស៊ីសែនតិចបំផុតក្នុងស្រះគឺ ៣.៥ មិល្លីក្រាមក្នុង ១ លីត្រទឹក។ កម្រិតរលាយខ្យល់អុកស៊ីសែនក្រោម ២ មីល្លីក្រាមក្នុង ១ លីត្រ នឹងធ្វើឱ្យបង្កងងាប់។ យើងអាចបង្កើនបរិមាណខ្យល់អុកស៊ីសែនក្នុងស្រះដោយ បញ្ចូលខ្យល់អុកស៊ីសែនក្នុងស្រះ ឬ ផ្លាស់ប្ដូរទឹក ។

**-កម្រិតថ្លានៃទឹកៈ** ត្រូវរក្សាកម្រិតថ្លានៃទឹកស្រះពី ២៥ ទៅ ៤០ សង់ទីម៉ែត្រ។ បើសិនជាកម្រិតថ្លានៃទឹកក្រោម ២៥ សង់ទីម៉ែត្រ មានន័យថា ទឹកស្រះល្អក់ ពេលនោះត្រូវផ្លាស់ប្ដូរទឹក និងរៀបចំការដាក់ចំណីឱ្យបានត្រឹមត្រូវ។ បើកម្រិតថ្លានៃទឹកលើសពី ៤០ សង់ទីម៉ែត្រ ត្រូវបន្ថែមជីសរីរាង្គ ឬ អសរីរាង្គ ដើម្បីបង្កើនពណ៌ទឹកស្រះ។ បើទឹកស្រះមានពណ៌បៃតងខ្ចី គឺទឹកមានលក្ខណៈល្អបំផុត។ បើសិនជាទឹកស្រះមានពណ៌បៃតងចាស់ ឬ ពណ៌ក្រម៉ៅត្រូវធ្វើការផ្លាស់ប្ដូរទឹក។

**-កម្រិតរឹងនៃទឹកៈ** ទឹកស្រះដែលមានកម្រិតរឹងសរុបពី ៥០ ទៅ ១០០ មីល្លី

ក្រាមក្នុង ១ លីត្រ គឺមានលក្ខណៈសមស្រប។ បើកម្រិតរឹងនៃទឹកក្រោម ៥០ មិលីក្រាមក្នុង ១ លីត្រ ត្រូវបន្ថែមកំបោរស ឬ ម្សៅសំបកងាវដើម្បីបង្កើនកម្រិតរឹងនៃទឹកដែលជួយឱ្យបង្កងងាយ**សក** និងងាយកកើតសំបកថ្មី ។

**គ-ការថែទាំបង្កងក្នុងស្រះ**

-ជានិច្ចកាលត្រូវតាមដានសកម្មភាពរបស់បង្កង បើឃើញបង្កងងើបនៅលើផ្ទៃទឹកខុសធម្មតា ត្រូវធ្វើការត្រួតពិនិត្យគុណភាពទឹកស្រះ ដើម្បីមានវិធានការកែលំអទាន់ពេលវេលា។ នៅពេលព្រឹកព្រលឹម បើសិនជាឃើញបង្កងហែលខុសធម្មតា ដោយប្រមូលផ្តុំគ្នានៅជ្រុងស្រះ នោះបញ្ជាក់ថាទឹកស្រះខ្វះខ្យល់អុកស៊ីសែន ដូចនេះយើងត្រូវបន្ថែមខ្យល់អុកស៊ីសែន ឬ ផ្លាស់ប្តូរទឹកជាបន្ទាន់ ។

-ត្រូវត្រួតពិនិត្យស្រះជារៀងរាល់ថ្ងៃ ដូចជា នៅមាត់ស្រះ ទ្វារទឹកចេញចូលស្រះ និងត្រូវកំចាត់សត្វចង្រៃ ដូចជា កណ្តុរ ពស់ កង្កែប ជាដើម ។ល។

## ៥-ការប្រមូលផលបង្កង

ក្រោយការចិញ្ចឹមរយៈពេលពី ៤ ទៅ ៥ ខែ បង្កងមានទម្ងន់មធ្យមពី ៣០ ទៅ ៥០ ក្រាមក្នុង ១ក្បាល ពេលនោះយើងអាចប្រមូលផលបានហើយ។ ការប្រមូលផលបង្កងចិញ្ចឹមមានពីរបែបគឺៈ ការប្រមូលផលរំលោះ និងការប្រមូលផលទាំងស្រុង។

**-ការប្រមូលផលរំលោះ** ក្រោយការចិញ្ចឹមបានរយៈពេល ៤ ខែ យើងអាចប្រមូលផលរំលោះ ដោយចាប់យកតែបង្កងដែលមានទំហំធំ និងបង្កង

មេ។ ចំណែកឯបង្កងឈ្មោល ត្រូវបានរក្សាទុកចិញ្ចឹមរហូតដល់ចុងរដូវ។ ការប្រមូលផលរបៀបនេះធ្វើឱ្យការចិញ្ចឹមទទួលទិន្នផលខ្ពស់ ពីព្រោះបង្កងឈ្មោលមានការលូតលាស់លឿននៅដំណាក់កាលចុងក្រោយ។

- **ការប្រមូលផលទាំងស្រុង៖** នៅពេលបង្កងភាគច្រើនមានទំហំធំក្លាយជាបង្កងសាច់ ហើយយើងអាចប្រមូលផលទាំងស្រុងបាន។ ដើម្បីងាយស្រួលក្នុងការប្រមូលផល យើងត្រូវបញ្ចេញទឹកស្រះពាក់កណ្ដាល រួចអូសអួនពី ៣ ទៅ ៤ ដង។ បន្ទាប់មក បង្កងនៅសល់តិចតួច យើងអាចបូមពង្រីងស្រះ និង ប្រមូលចាប់ទាំងអស់។ ក្រោយពេលប្រមូលផលរួច ត្រូវប្រោះបង្កងទុកក្នុងអាង ឬ ក្នុងធុង ដែលមានដាក់ខ្យល់អុកស៊ីសែន ដោយរើសចេញនូវបង្កងតូចៗ ឬ ត្រីល្អិតមុនពេលលក់។ ត្រូវដឹកជញ្ជូនបង្កង ដោយមានដាក់ខ្យល់អុកស៊ីសែន ដើម្បីធ្វើឱ្យបង្កងរស់បានយូរ និងលក់បានតម្លៃថ្លៃ។





*ការប្រមូលផលបង្កង*

# រដ្ឋបាលជលផល

## តារាងរាយនាមមជ្ឈមណ្ឌលផលិតកូនត្រីពូជរដ្ឋ និងកសិដ្ឋានកសិករ ដែលមានផលិតកូនបន្លង

| ល.រ | ឈ្មោះអង្គភាព/កសិករ | ទូរស័ព្ទ | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង |
|---|---|---|---|---|---|
| I | **មជ្ឈមណ្ឌលផលិតកូនត្រីពូជរដ្ឋ** | | | | |
| ១ | មជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍វារីវប្បកម្ម ទឹកសាប បាទី) | 012 940 168<br>097 8990 999 | បាទី | បាទី | ពាមរក៍ (ព្រៃវែង) |
| II | កសិករផលិតកូនត្រីពូជ | | | | |
| ក | **ខេត្តតាកែវ** | | | | |
| ១ | ខៀវ សំ | 012 415 220 | ត្រពាំងក្រោច | លាយបូ | ត្រាំកក់ |
| ២ | វិន ឈឿន | 012 843 725 | ទឹកថ្លា | គួស | ត្រាំកក់ |
| ៣ | សោម ហាក់ | 012 583 015 | ព្រៃកប្បាស | តាភេម | ត្រាំកក់ |
| ៤ | ព្រំ វ៉ាត | 092 253 785 | ព្រៃសំបួរ | អង្គរបូរី | អង្គរបូរី |
| ខ | **ខេត្តកំពត** | | | | |
| | ម៉ម សារ៉ាន់ | 012 968 017 | ដំណាក់ទ្រព្យ | ក្រាំងស្នាយ | ឈូក |

ឧបត្ថម្ភ
បោះពុម្ពផ្សាយដោយៈ
លោកជំទាវ មាស ស៊ីថន ណៅ ធួក










នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អាសយដ្ឋានលេខ ១៨៦ មហាវិថីព្រះនរោត្តម ប្រអប់សំបុត្រ ៨៣៥
រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥) ២៣ ៩៩៦ ៣៨០